

# ពពកច្រណែននឹងព្រះអាទិត្យ

Vann Samrach

Let's Read

The Asia Foundation



ពេលព្រឹកព្រហាមស្រាងៗ ព្រះអាទិត្យបានបញ្ចេញពន្លឺពណ៌មាសយ៉ាងស្រស់ត្រកាល។ មនុស្សម្នាលាន់មាត់កោតសរសើរពីព្រះអាទិត្យគ្រប់ៗគ្នា ថាថ្ងៃរះភ្លឺច្បាស់ល្អណាស់។



ពពកបានឮ ក៏មានចិត្តច្រណែនចង់យកឈ្នះព្រះអាទិត្យដើម្បី ឱ្យមនុស្សបែរចិត្តមកស្រឡាញ់ និងកោតសរសើរខ្លួនវិញ។ ពពក៖ «ឯងមានអីអស្ចារ្យ ខ្លួនមានតែមួយហើយជះពន្លឺក្តៅទៀត តែខ្ញុំវិញមានគ្នាច្រើន អាចហោះហើរ ហើយអាចប្តូររូបរាងបានច្រើនទៀត។» ព្រះអាទិត្យមិនរវល់ពីសម្តីពពកឡើយ គេនៅតែបន្តខំប្រឹងបញ្ចេញពន្លឺដល់ភពផែនដី។



ពេលថ្ងៃត្រង់ ពពកឃើញព្រះអាទិត្យប្រឹងបញ្ចេញកម្ដៅបែបនេះ ក៏គិតម្នាក់ឯង៖ «ព្រះអាទិត្យបញ្ចេញកម្ដៅខ្លាំងម្ល៉ឹងៗ មនុស្សទាំងអស់ប្រាកដជាត្រូវការទឹកភ្លៀង។ អ៊ុំ... ឱកាសយើងបានមកដល់ហើយ!»



រំពេចនោះ ពន្លឺព្រះអាទិត្យស្រាប់តែថមថយទៅៗ ធ្វើឱ្យភពផែនដីប្រែជាងងឹត។ មនុស្សម្នាងឿងឆ្ងល់យ៉ាងខ្លាំង មិនដឹងថាមានអ្វីកើតឡើងនោះឡើយ។



អ៊ុំ...តាមពិតពពកកំពុងតែប្រមូលផ្តុំគ្នាក្រាស់ឃ្មឹកដើម្បីបាំង ពន្លឺព្រះអាទិត្យ។ ពពកសើចចំអកឱ្យព្រះអាទិត្យ ៖«ហាស់.. ហាស់.. ហា.. ចាំមើលឯងខ្លាំងដល់ណាទៀត!» ព្រះអាទិត្យ តបទាំងញញឹម៖«អរគុណពពក ដែលបានឈរបាំងខ្ញុំដើម្បី បន្ថយកម្ដៅផែនដីបែបនេះ។»



ពពកបានឮពាក្យព្រះអាទិត្យហើយ កាន់តែខឹងហើយខំប្រឹង ប្រមូលគ្នាច្រើនឡើងៗ រហូតធ្វើឱ្យផែនដីបាត់ពន្លឺស្ទើរមើល អ្វីមិនឃើញអស់រយៈពេលបីថ្ងៃបីយប់។ ព្រះអាទិត្យឃើញ បែបនេះ គិតថា៖ «មិនបានទេ! ខ្ញុំត្រូវតែខំប្រឹងប្រើកម្លាំង បញ្ចេញពន្លឺដើម្បីបំភ្លឺផែនដី បើមិនដូច្នេះទេ មនុស្ស សត្វ រុក្ខជាតិប្រាកដជាមិនអាចរស់បានស្រួលឡើយ» ព្រះអាទិត្យ ខំប្រឹងផ្លុំពពកចេញ ប៉ុន្តែនៅតែមិនអាចបំបែកហ្វូងពពកបាន ឡើយ។



ចំណែកឯពពកវិញ ខំប្រឹងបង្កើនកម្លាំងប្រមូលផ្តុំគ្នាកាន់តែច្រើនឡើងៗ រួចក៏ទម្លាក់ទឹកភ្លៀងចុះសព្វទិសទី។



ពេលឃើញភ្លៀងធ្លាក់ មនុស្សម្នាត្រេកអរនឹងទឹកភ្លៀងណាស់ ព្រោះធ្វើឱ្យអាកាសធាតុប្រែត្រជាក់ស្រួល។



ពពកក៏សប្បាយចិត្ត ហើយរឹតតែមានអំនួតលើខ្លួនឯង ប្រឹងទម្លាក់ទឹកភ្លៀងកាន់តែខ្លាំងឡើងរហូតកើតជាទឹកជំនន់លិចផ្ទះអ្នកភូមិ។



ពេលជំនន់លេចភូមិ មនុស្សម្នាក៏កើតការមិនសប្បាយចិត្តជាខ្លាំង ហើយខឹងសម្បារនឹងភ្លៀងវិញ។ ប៉ុន្តែពពកមិនខ្វល់ វាគិតតែធ្វើយ៉ាងណាយកឈ្នះលើព្រះអាទិត្យ។



ពពកប្រឹងទម្លាក់ទឹកភ្លៀងរហូតខ្សោះទឹកអស់ពីខ្លួន ហើយពេលនោះ រូបរាងរបស់វាក៏ស្រាប់តែបាត់បន្តិចម្តងៗ។



ក្រោយពេលពពករសាត់បាត់ទៅ ព្រះអាទិត្យក៏អាចបញ្ចេញពន្លឺដល់ផែនដីបានបន្តទៀត។ កម្ដៅព្រះអាទិត្យក៏រំហួតចំហាយទឹកឡើង ទឹកជំនន់ក៏បានស្រកជាបណ្ដើរៗ។



ក្រោយពេលមានចំហាយទឹកហួតឡើងលើអាកាស រូបរាងពពកក៏លេចចេញមកវិញ។ ពេលនោះ ពពកក៏បានយល់ថា៖«ពេលនេះខ្ញុំដឹងហើយ តាមពិតខ្លួនខ្ញុំកើតចេញពីកម្ដៅព្រះអាទិត្យដែលបានរំហួតចំហាយទឹកឡើងពីផែនដី...»



ពពកក៏បានអរគុណចំពោះព្រះអាទិត្យថា៖«ខ្ញុំអរគុណណាស់ព្រះអាទិត្យ ដែលឯងបានធ្វើឱ្យខ្ញុំមានរូបរាងឡើងវិញ។ តើខ្ញុំអាចធ្វើជាមិត្តរបស់ឯងបានដែរឬទេ?» ព្រះអាទិត្យតបទាំងញញឹមថា៖«បាន!សម្លាញ់»



តាំងពីពេលនោះមក ពពក និងព្រះអាទិត្យបានសហការគ្នា យ៉ាងរីករាយ ហើយបំពេញតួនាទីរៀងៗខ្លួន។ ព្រះអាទិត្យ គឺជាអ្នកបំភ្លឺផែនដី។ ចំណែកឯពពក គឺជាអ្នកផ្តល់ទឹកភ្លៀង។





Generously supported by SMART/

# Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ពពកច្រណែននឹងព្រះអាទិត្យ (The Jealous Cloud)*, Author: Vann Samrach.
Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/